គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee for Cambodia
Comité de Coopération Pour le Cambodge

**ទស្សនវិស័យ:** ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនិងប្រជាធិបតេយ្យសម្រាប់ប្រទេសកម្ពុជា
**Vision:** Sustainable and democratic development for Cambodia

# ទស្សនទាន

# កិច្ចប្រជុំសម្រាប់សមាជិករបស់អង្គការ គសក លើកទី២៧៧ ស្តីពី «ការរៀបចំលក្ខន្តិកៈ និងការបិទអង្គការមិនមែនរដ្ឋាភិបាលដោយអនុលោមតាមច្បាប់»

**កាលបរិច្ឆេទ៖ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៤ (ម៉ោង៖ ៨:00 ព្រឹក - ១២:00 ថ្ងៃត្រង់)**

**ទីតាំង៖ សណ្ឋាគារ Anik Palace Hotel (លេខ១៤, ផ្លូវ ២៧៨, ខណ្ឌបឹងកេងកង)**

## សេចក្តីផ្តើម៖

ការចែករំលែកការអនុវត្តល្អបំផុត និងការពង្រឹងសមត្ថភាពសមាជិកលើប្រធានបទពាក់ព័ន្ធ សំខាន់ៗ គឺជាការផ្តោតសំខាន់សម្រាប់គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គសក) ជាអង្គការដែលមានសមាជិកភាពធំជាងគេ ដែលមានសមាជិកច្រើនជាង ១៨០ស្ថាប័ន ដែលកំពុងធ្វើការលើវិស័យផ្សេងៗគ្នាក្នុងប្រទេសកម្ពុជា។

លក្ខន្តិកៈ ត្រូវបានចាត់ទុកថាជាឯកសារផ្លូវច្បាប់ ដែលកំណត់ពីរបៀបដែលស្ថាប័នមួយត្រូវបានគ្រប់គ្រង និងធ្វើប្រតិបត្តិការ។ ការប្រើប្រាស់សមស្រប នៃលក្ខន្តិកៈរបស់ស្ថាប័ន មិនត្រឹមតែផ្តល់នូវរចនាសម្ព័ន្ធចាំបាច់ដល់អភិបាលកិច្ចប្រកបដោយប្រសិទ្ធភាពប៉ុណ្ណោះទេ ប៉ុន្តែវាក៏លុបបំបាត់ការធ្វើការដោយការប៉ាន់ស្មាននិងដោយគ្មានប្រសិទ្ធិភាពក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលផងដែរ។ អភិបាលកិច្ចល្អ បង្កើតមូលដ្ឋានគ្រឹះសម្រាប់ការងារល្អ។ ដោយសារលក្ខន្តិកៈ គឺជាឯកសារសំខាន់មួយ ដូច្នេះអ្វីដែលត្រូវដាក់បញ្ចូល និងរបៀបប្រើប្រាស់ គួរត្រូវបានយកចិត្តទុកដាក់ខ្លាំង។ អាស្រ័យហេតុនេះ មានចម្ងល់ និងបញ្ហាប្រឈមនានាពីសណាក់អង្គការសមាជិក ស្តីពីគោលការណ៍ណែនាំជាក់ស្តែងនៃការបង្កើតលក្ខន្តិកៈសម្រាប់អង្គការរបស់ពួកគេក្នុងទំរង់ត្រឹមត្រូវ មានលក្ខណៈស្តង់ដា និងទទួលស្គាល់ដោយម្ចាស់ជំនួយ និងអាជ្ញាធរ។ បញ្ហាប្រឈមមួយផ្សេងទៀត គឺពាក់ព័ន្ធទៅនឹងដំណើរការនៃការរំលាយ ឬការបិទអង្គការ។ វាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការយល់ដឹង ការរៀបចំជាដំណាក់កាល និងភារកិច្ចដែលពាក់ព័ន្ធនឹងការរំលាយអង្គការមិនមែន រដ្ឋាភិបាល ព្រោះវាអាចជាការណែនាំសម្រាប់ការបង្កើតដំណើរការ នៃការផ្លាស់ប្តូរអន្តរកាលប្រកបដោយការគោរព និងកិត្តិយស ជាពិសេសដើម្បីអនុលោមតាមការកំណត់របស់ច្បាប់។

ដើម្បីឆ្លើយតបទៅនឹងកង្វល់ទាំងនេះ និងដើម្បីបង្កើនការយល់ដឹងក្នុងចំណោមសមាជិករបស់ អង្គការ គសក អំពីរបៀបរៀបចំលក្ខន្តិកៈ និងដំណើរការផ្លូវច្បាប់នៃការបិទអង្គការបានត្រឹមត្រូវ អង្គការ គសក នឹងធ្វើរៀបចំវេទិកាចែករំលែកជាមួយអង្គការសមាជិកនៅក្នុងកិច្ចប្រជុំពីរខែម្តង លើកទី២៧៧ នៅខែកញ្ញា ឆ្នាំ២០២៤ ខាងមុខនេះ។

ដោយផ្អែកលើលក្ខន្តិកៈរបស់អង្គការ គសក កិច្ចប្រជុំសមាជិករៀងរាល់ពីរខែម្តងត្រូវបានរៀបចំឡើងសម្រាប់អ្នកចូលរួមដែលជាអ្នកតំណាងប្រទេស/នាយកប្រតិបត្តិ និងអ្នកដឹកនាំជាន់ខ្ពស់/អ្នកគ្រប់គ្រងនៃអង្គការសមាជិក គសក ដើម្បីចូលរួម និងចែករំលែកចំណេះដឹង និងបទពិសោធន៍ កង្វល់រួមលើបញ្ហាប្រឈមនៃការអភិវឌ្ឍន៍ និងបញ្ហាសំខាន់ៗផ្សេងទៀតនៃសមាជិក គសក ដែលត្រូវដោះស្រាយជាមួយគ្នា។

## គោលបំណង៖

1. ស្វាគមន៍សមាជិកថ្មី បង្កើនទំនាក់ទំនងរវាងសមាជិក និងការចែករំលែកការងាររបស់សមាជិក។
2. លើកកម្ពស់ការយល់ដឹងអំពីការរៀបចំ និងកែសម្រួលលក្ខន្តិកៈ។
3. ចែករំលែកអំពី នីតិវិធីក្នុងការបិទស្ថាប័នអង្គការមិនមែនរដ្ឋាភិបាលដោយអនុលោមតាមច្បាប់។

## របៀបវារៈ៖

| ម៉ោង | ខ្លឹមសាររបៀបវារៈ | អ្នកសម្របសម្រួល |
|---|---|---|
| ០៨:០០ - ០៨:៣០ | **ចុះឈ្មោះ និងទំនាក់ទំនង** | អ្នកចូលរួមទាំងអស់ |
| ០៨:៣០ - ០៨:៣៥ | **គោរពភ្លេងជាតិ** | អ្នកកាន់កម្មវិធី៖ **កញ្ញា សាំង សុចន្ទ្រា** |
| ០៨:៣៥ - ០៨:៥០ | **មតិស្វាគមន៍ និងបើកកម្មវិធី**<br>បច្ចុប្បន្នភាពពី គសក | **លោកស្រី ស៊ិន ពុទ្ធារី**<br>នាយិកាប្រតិបត្តិ អង្គការ គសក |
| ០៨:៥០ - ០៩:២០ | **ចែករំលែក និងធ្វើបច្ចុប្បន្នភាពដោយសមាជិកថ្មី**<br>- អង្គការនារីដើម្បីសន្តិភាព (WPM)<br>- សមាគមនិរន្តរភាពដីដើម្បីជីវិត (SSLA) | |
| ០៩:២០ - ០៩:៣០ | **សម្រាកអាហារសម្រន់ និងទំនាក់ទំនង** | អ្នកចូលរួមទាំងអស់ |
| ០៩:៣០ - ១០:៣០ | **បទបង្ហាញស្តីពីការរៀបចំលក្ខន្តិកៈសម្រាប់អង្គការមិនមែនរដ្ឋាភិបាល៖**<br>- អ្វីទៅជាលក្ខន្តិកៈ? និងទំរង់នៃលក្ខន្តិកៈ?<br>- តើអ្វីខ្លះដែលត្រូវមានបញ្ចូលនៅក្នុងលក្ខន្តិកៈ?<br>- គម្រូស្តង់ដាលក្ខន្តិកៈ។<br>- ដំណើរការក្នុងការកែសម្រួលលក្ខន្តិកៈ។ | **លោកស្រី ស៊ូ ភិរ៉ានី** អនុប្រធាននាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ |
| ១០:៣០ - ១១:៥០ | **បទបង្ហាញស្តីពីដំណើរការនៃការបិទបញ្ចប់អង្គការមិនមែនរដ្ឋាភិបាលដោយអនុលោមតាមការកំណត់នៃច្បាប់៖**<br>- តើពេលណា និងអ្នកណា គួរដាក់លិខិតទៅក្រសួងមហាផ្ទៃ?<br>- តើឯកសារសំខាន់ៗអ្វីខ្លះដែលត្រូវភ្ជាប់មកជាមួយ?<br>- តើអង្គការមិនមែនរដ្ឋាភិបាល អាច និងមិនអាចធ្វើអ្វីខ្លះ ក្នុងអំឡុងពេលដំណើរការបិទអង្គការ?<br>- តើអង្គការមិនមែនរដ្ឋាភិបាល អាចទទួលបានការឆ្លើយតបពីសំណាក់ក្រសួងមហាផ្ទៃ ក្នុងរយៈពេលប៉ុន្មាន បន្ទាប់ពីពួកគេបានជូនដំណឹងអំពីការបិទបញ្ចប់សកម្មភាពអង្គការរបស់ពួកគេ? | **លោក ឡុង សារៈ** ប្រធានការិយាល័យកិច្ចការអង្គការមិនមែនរដ្ឋាភិបាល នាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ |
| ១១:៥០ - ១២:០០ | **បូកសរុប និងមតិបិទកម្មវិធី** | **លោក ច័ន្ទ ភក្តី** សមាជិកគណៈកម្មាធិការប្រតិបត្តិនៃអង្គការ គសក និងជាតំណាងប្រចាំប្រទេសអង្គការ ការីតាសអូស្ត្រាលី |
| ពិសារអាហារថ្ងៃត្រង់រួមគ្នា | | |

**សំគាល់៖** - កិច្ចប្រជុំនេះនឹងមានការបកប្រែជាភាសាខ្មែរ និងអង់គ្លេស។ អង្គការ គសក សូមរក្សាសិទ្ធិក្នុងការកែសម្រួលរបៀបវារៈ និងពេលវេលា អាស្រ័យលើពេលវេលារបស់វាគ្មិន និងបញ្ហាផ្សេងៗ។ ឯកសារផ្សេងៗ រួមទាំងរូបភាព និងខ្លឹមសារសំខាន់ៗ នឹងត្រូវបានដាក់បញ្ចូលជាសាធារណៈក្នុងគេហទំព័រ និងប្រព័ន្ធទំនាក់ទំនងសង្គម តាមតំណភ្ជាប់ https://www.ccc-cambodia.org/en/resources/event-archives www.facebook.com/CCCsince1990 www.youtube.com/CCCambodia

- សូមមេត្តាចុះឈ្មោះជាមុនដើម្បីចូលរួមក្នុងកិច្ចប្រជុំនេះ តាមរយៈតំណភ្ជាប់៖ https://www.ccc-cambodia.org/kh/resources/event-calendar/2024-09-26/ccc-members-277th-bi-monthly-meeting-on-developing-by-laws-and-closing-non-profit-organization-complying-with-law



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh